កំណត់សំគាល់ ៖ សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**តុលាការរដ្ឋប្បវេណី**

-សំណុំរឿងរដ្ឋប្បវេណី លេខ ២២៣
ចុះថ្ងៃទី ២៤-០១-២០១៧
-សាលក្រមរដ្ឋប្បវេណី
លេខ ៨២០ "ជ១"
ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨

**ចៅក្រមជំនុំជម្រះ**

លោក **គី ម៉ានេវ៉ា** អនុប្រធាននៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **ស៊ឹម សុផល្លា** ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ៖**

ជ ភេទប្រុស អាយុ៣៦ឆ្នាំ មុខរបរ មានទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិ រាជធានីភ្នំពេញ ។

**ចុងចម្លើយ៖**

ច ភេទប្រុស អាយុ៣០ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ រាជធានីភ្នំពេញ ។

## អង្គហេតុ និង ចំណុចវិវាទ

### ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖

១.ឲ្យចុងចម្លើយប្រគល់ប្រាក់ដើមចំនួន១,២០០$ (មួយពាន់ពីររយ)ដុល្លារអាមេរិក ។
២.ឲ្យចុងចម្លើយបង់ការប្រាក់ ៥% ចាប់ពីខែកញ្ញា ឆ្នាំ២០១៦ ។
៣.ឲ្យចុងចម្លើយបង់ជំងឺចិត្តថ្លៃចំណាយផ្សេងៗ និងការខាតបង់ពេលវេលាចំនួន ២លានរៀល ។
៤.ប្រាក់ពន្ធលើកម្មវត្ថុបណ្តឹង និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ ។

### ខ.ការសង្ខេបអំពីរឿងក្តី ៖

កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ភាគីចុងចម្លើយឈ្មោះ ច បានមកសុំខ្ចីប្រាក់របស់ខ្លួន ចំនួន ២,០០០(ពីរពាន់) ដុល្លារអាមេរិក ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវ និងសន្យាសងប្រាក់ដើមមកឲ្យខ្លួនវិញ នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៦ បន្ទាប់ពីបានខ្ចីប្រាក់ខ្លួនរួចមក ភាគីចុងចម្លើយតែងតែបង់ការប្រាក់ជាទៀងទាត់ តែលុះដល់ថ្ងៃកំណត់សងប្រាក់ដើម ស្រាប់តែភាគីចុងចម្លើយ ពុំបានយកប្រាក់មកសងតាមកាលកំណត់ឡើយ ពេលនោះខ្លួនក៏បានទាក់ទងទាមទារ ពេលនោះភាគីចុងចម្លើយបានយកប្រាក់ចំនួន ៨០០ ដុល្លារមកសងខ្លួន ហើយសន្យាថានិងសងឲ្យគ្រប់ ចំនួននៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៦ លុះដល់ថ្ងៃកំណត់ខ្លួនក៏បានទៅទារប្រាក់ពីចុងចម្លើយ ពេលនោះស្រាប់ តែភាគីចុងចម្លើយបានគេចវេសមិនព្រមសងប្រាក់ទេ ហើយគេចមិនព្រមជួបខ្លួនថែមទៀតផង ។

## ឃ. អង្គហេតុដែលអះអាងដោយដើមចោទ ៖

លោក ដ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួននៅតែសុំប្តឹងទាមទារប្រាក់ពីឈ្មោះ ច ដូចនៅក្នុងពាក្យបណ្តឹងដដែល ។ ដោយកាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ ភាគីចុងចម្លើយឈ្មោះ ច បានមកសុំខ្ចីប្រាក់របស់ខ្លួន ចំនួន ២,០០០(ពីរពាន់) ដុល្លារអាមេរិក ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវ និងសន្យាសង់ប្រាក់ដើមមកឲ្យខ្លួនវិញ នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៦ ហើយសន្យាបង់ការប្រាក់ ៣% ក្នុងមួយខែ ហើយដើមចោទបានបង់ការប្រាក់បានចំនួន ០៣ខែ ចំនួនសរុប ១៨០$ លុះដល់កំណត់សងប្រាក់ដើម ស្រាប់តែឈ្មោះ ច ពុំបានយកប្រាក់មកសងតាមកាលកំណត់ទេ ក្រោយមកបានទាក់ទងគ្នាតាមទូរស័ព្ទ ចុងចម្លើយក៏បានសងលុយលើកទី១ ចំនួន៥០០$ មិនចាំថ្ងៃ ចុងឆ្នាំ២០១៦ និងលើកទីពីរចំនួន ៣០០$ មិនចាំថ្ងៃចុងឆ្នាំ២០១៦ សរុបទាំងពីរលើកសងបានចំនួន ៨០០$ ដូច្នេះប្រាក់ដើមនៅសល់ ១២០០$ ទៀត ក្រោយមកចុងចម្លើយ សន្យាសងប្រាក់តែមិនបានសងបន្ថែមទេ គេចវេសរហូតមកដល់សព្វថ្ងៃ ។

## ង. អង្គហេតុដែលអះអាងដោយចុងចម្លើយ ៖

លោក ច បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនពិតជាបានខ្ចីប្រាក់ ២,០០០$ ដុល្លារអាមេរិក ពីដើមចោទពិតប្រាកដមែន ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវនិងបានបង់ការប្រាក់ ត្រឹមត្រូវហើយ បានសងទៅដើមបណ្តឹងលើកទី១ ចំនួន ១០០០$ (មួយពាន់) ដុល្លារអាមេរិក នៅខែមិនចាំ ឆ្នាំ២០១៦ តាមរយៈឈ្មោះ ស ច ភេទប្រុស ត្រូវជាបងប្រុសរបស់មិត្តភក្តិខ្លួន លើកទី២ និងលើកទី៣ សងចំនួន ៨០០ ដុល្លារ ដូច្នេះខ្លួននៅខ្វះតែ ២០០ដុល្លារ(ប្រាក់ដើម) ហើយខ្លួនសុំណូមពរសងប្រាក់ដើមតែ ២០០ ដុល្លារ និងការប្រាក់អាក់ខានចំនួន ១០០ដុល្លារ សរុបចំនួន ៣០០ដុល្លារ ហើយនិងស្នើសុំដាក់ជូនសាក្សីឈ្មោះ ស ច នៅពេលក្រោយ ។

## ការពិនិត្យភស្តុតាង

ភស្តុតាងជាឯកសាររបស់ដើមចោទ ៖

- កិច្ចសន្យាខ្ចីប្រាក់ រវាងភាគីឲ្យខ្ចីប្រាក់ឈ្មោះ ដ និងភាគីខ្ចីប្រាក់ឈ្មោះ ច ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១៦ ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការ យល់ឃើញថា ៖

១.ពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ របស់ឈ្មោះ ដ ភេទប្រុស អាយុ៣៦ឆ្នាំ មានលក្ខណៈត្រឹមត្រូវ សាលាដំបូងរាជធានីភ្នំពេញ មានដែនសមត្ថកិច្ចដើម្បីវិនិច្ឆ័យស្របច្បាប់នូវ ពាក្យបណ្តឹងហើយចេញសាលក្រមបានតាមមាត្រា៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-តាមមាត្រា៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា តុលាការត្រូវប្រឹងប្រែងដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណី ឲ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹង រដ្ឋប្បវេណីដោយសុចរិតនិងសោះត្រង់ ។

៣-តាមកិច្ចសន្យាខ្ចីប្រាក់ រវាងភាគីឲ្យខ្ចីប្រាក់ឈ្មោះ ដ និងភាគីខ្ចីប្រាក់ឈ្មោះ ច ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ អាចបញ្ជាក់បានថាចុងចម្លើយឈ្មោះ ច ពិតជាបានធ្វើកិច្ចសន្យាខ្ចីប្រាក់ពីឈ្មោះ ដ ពិតប្រាកដមែន ស្របតាមការអះអាងរបស់ដើមចោទ ហើយចុងចម្លើយក៏ទទួលស្គាល់ពីការធ្វើកិច្ចសន្យាខ្ចីប្រាក់នេះប្រាកដមែន។

៤-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ ដ បានឲ្យដឹងថា៖ ចុងចម្លើយ បានមកសុំខ្ចីប្រាក់របស់ខ្លួន ចំនួន ២,០០០(ពីរពាន់) ដុល្លារអាមេរិក និងសន្យាសង់ប្រាក់ដើមមកឲ្យខ្លួនវិញ នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៦ ហើយសន្យាបង់ការប្រាក់ ៣% ក្នុងមួយខែ ហើយដើមចោទបានបង់ការប្រាក់បានចំនួន ០៣ខែ ចំនួនសរុប ១៨០$ លុះដល់កំណត់សងប្រាក់ដើម ស្រាប់តែឈ្មោះ ច ពុំបានយកប្រាក់មកសងតាមកាលកំណត់ទេ ក្រោយមកបានទាក់ទងគ្នាតាមទូរស័ព្ទ ចុងចម្លើយក៏បានសងលុយលើកទី១ ចំនួន៥០០$ មិនចាំថ្ងៃ ចុងឆ្នាំ២០១៦ និងលើកទីពីរចំនួន ៣០០$ មិនចាំថ្ងៃចុងឆ្នាំ២០១៦ សរុបទាំងពីរលើកសងបានចំនួន ៨០០$ ដូនច្នេះប្រាក់ដើមនៅសល់ ១២០០$ ទៀត ។ ២៣៥

៥-តាមសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ ច បានឱ្យដឹងថា៖ ខ្លួនបានសងចំនួន៣លើកឱ្យទៅដើមបណ្ដឹង ដោយលើកទី១ ចំនួន ១០០០$ (មួយពាន់) ដុល្លារអាមេរិក នៅខែមិនចាំ ឆ្នាំ២០១៦ តាមរយៈឈ្មោះ ស ច ភេទប្រុស ត្រូវជាបងប្រុសរបស់មិត្តភក្ដិខ្លួន លើកទី២ និងលើកទី៣ សងចំនួន ៨០០ ដុល្លារ ដូច្នេះខ្លួននៅខ្វះតែ ២០០ដុល្លារ (ប្រាក់ដើម) ទេ ។

-ភាគីចុងចម្លើយបានស្នើឱ្យតុលាការកោះហៅសាក្សីឈ្មោះ ស ច ដើម្បីមកធ្វើការបញ្ជាក់ តុលាការក៏បានចេញដីកាកោះហៅ និងបានបញ្ជូនទៅដល់ទីលំនៅរបស់សាក្សី ប៉ុន្តែសាក្សីពុំបានចូលមកតុលាការតាមការកោះហៅឡើយ ដូច្នេះពុំមានភស្តុតាងណាមួយមកអះអាងដើម្បីឱ្យតុលាការជឿជាក់ថាពិតជាបានបង់ប្រាក់ដូចដែលចុងចម្លើយបានអះអាងនោះទេ ។

៦-ដើមចោទបានទាមទារឱ្យតុលាការសម្រេចចេញសាលក្រម ដូចខាងក្រោម ៖

៦.១-ឱ្យចុងចម្លើយប្រគល់ប្រាក់ដើមចំនួន ១,២០០$ (មួយពាន់ពីររយ)ដុល្លារអាមេរិក ។

៦.២-ឱ្យចុងចម្លើយបង់ការប្រាក់ ៥% គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៦ ។

-ការទាមទារក្នុងចំណុច ៦.១ គឺជាការទាមទារប្រាក់ (ការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ) ដោយហេតុថា ភាគីចុងចម្លើយបានបង់ប្រាក់ចំនួន ៨០០$ ដោយនៅខ្វះប្រាក់ចំនួន ១២០០$ ទៀត ពុំទាន់បានបង់ទៅឱ្យដើមចោទ តុលាការគប្បីសម្រេចតាមការទាមទារ ។ ចំពោះចំណុច ៦.២ ដែលភាគីដើមចោទបានទាមទារលើការប្រាក់ ៥% ក្នុងមួយខែ តុលាការឃើញថា ការទាមទារនេះពុំស្របទៅ នឹងអត្រាការប្រាក់ដែលច្បាប់បានកំណត់ឡើយ ដោយយោងទៅតាម **ប្រកាសស្ដីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត លេខ១២៨ ក.យ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌** បានកំណត់អត្រាការមិនឱ្យលើសពី ១៨% (ដប់ប្រាំបី) ភាគរយ ក្នុង ១(មួយ)ឆ្នាំ ដូច្នេះតុលាការគប្បីពិនិត្យ និងសម្រេចតាមច្បាប់ ។

៦.៣-ឱ្យចុងចម្លើយបង់ជំងឺចិត្តថ្លៃចំណាយផ្សេងៗ និងការខាតបង់ពេលវេលាចំនួន ២លានរៀល ។

-ហេតុនេះតុលាការគប្បីពិចារណា ទៅតាមភាពជាក់ស្ដែងដែលសមរម្យ ។

៧-ប្រាក់ប្រដាប់ក្ដីត្រូវបានអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្ដីសម្រេចបញ្ចប់

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច សងប្រាក់ទៅដើមចោទឈ្មោះ ដ នូវ៖

១.១.សងប្រាក់ដើមដែលនៅសល់ចំនួន ១,២០០$ (មួយពាន់ពីររយ) ដុល្លារអាមេរិក ទៅឱ្យដើមចោទ ។

១.២.ច្រានចោលការទាមទារអត្រាការប្រាក់ ៥% ក្នុងមួយខែ របស់ដើមចោទ និងកំណត់យកអត្រាការប្រាក់ត្រឹម ១.៥% ក្នុងមួយខែ គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៦ រហូតដល់សងគ្រប់ចំនួន ។

១.៣.បង់ថ្លៃជំងឺចិត្ត និងចំណាយផ្សេងៗចំនួន ១,០០០,០០០ (មួយលាន) រៀល ។

២.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ។

បើកសិទ្ធិប្ដឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។ PVC

**ចៅក្រម**

ហត្ថលេខា និងត្រា **គី ម៉ានេវ៉ា**

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃច័ន្ទ១៤រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩

**បានឃើញ**

**ចៅក្រម**

**គី ម៉ានេវ៉ា**

**ក្រឡាបញ្ជី**

**ស៊ីម សុផល្លា**